**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

**ក្រុមការងារយេនឌ័រ**

**សូមគោរពជម្រាបជូន**

**លោកជំទាវ រដ្ឋលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ**

**តាមរយៈ** ៖ លោកជំទាវ អគ្គលេខាធិការ និងជាសមាជិកក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ

**យោង** ៖ ការចាត់តាំងពីលោកជំទាវ អគ្គលេខាធិការ កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០២៤

**កម្មវត្ថុ៖** របាយការណ៍ស្តីពីកិច្ចប្រជុំពិភាក្សាប្រមូលធាតុចូល ដើម្បីរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (2024-2029)

តបតាមកម្មវត្ថុខាងលើ នាងខ្ញុំសូមជម្រាបជូនលោកជំទាវ ជ្រាបថា បន្ទាប់ពីទទួលបានការចាត់តាំងរបស់លោកជំទាវអគ្គលេខាធិការ នៅព្រឹកថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤ នាងខ្ញុំបានចូលរួម កិច្ចប្រជុំពិភាក្សាប្រមូលធាតុចូល ដើម្បីរៀបចំផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (2024-2029) ដឹកនាំដោយលោកជំទាវ អ៊ុង សុភាវី រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារយេនឌ័ររបស់ក្រសួងមហាផ្ទៃ។ នៅក្នុងកិច្ចប្រជុំមានសមាភាពពីអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ជាប្រធាន អនុប្រធាន និងសមាជិកនៅក្នុងក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃទាំងអស់ សរុប ៤២រូប ក្នុងនោះបុរសចំនួន ៧រូប ។

របៀបវារៈនៃកិច្ចប្រជុំរួមមាន៖

១- មតិសំណេះសំណាល និងថ្លែងអំណរគុណដល់ក្រុមការងារតាមបណ្តាអង្គភាពចំណុះក្រសួងមហាផ្ទៃ ដោយលោកជំទាវ អ៊ុង សុភាវី

២- ការណែនាំពីការផ្តល់របាយការណ៍៩ខែ និងរបាយការប្រចាំឆ្នាំ ទៅក្រុមប្រឹក្សាជាតិដើម្បីស្ត្រី និងក្រសួងកិច្ចការនារី ដោយ លោកជំទាវ សំ រចនា

៣- ពិនិត្យមើលសេចក្តីព្រាង និងការប្រមូលធាតុចូលសម្រាប់ការរៀបផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ (២០២៤ - ២០២៩) របស់ក្រសួងមហាផ្ទៃដោយ លោកជំទាវ សំ រចនា

៤- កិច្ចសហការគ្នាជាផ្លូវការ ដើម្បីផ្តល់ទិន្នន័យ ដោយ លោកជំទាវ សំ រចនា

៥- ធ្វើបច្ចុប្បន្នភាពទិន្នន័យមន្ត្រីរាជការក្របខណ្ឌក្រសួងមហាផ្ទៃតាមបណ្តាអង្គភាពនីមួយៗ ដោយ លោកជំទាវ សំ រចនា

៦- ស្នើសុំធ្វើរបាយការណ៍របស់ក្រុមការងារយេនឌ័រនៅថ្នាក់ក្រោមជាតិ ដោយ លោកជំទាវ សំ រចនា

បន្ទាប់ពីលោកជំទាវ អ៊ុង សុភាវី បានធ្វើការថ្លែងអំណរគុណ និងកោតសរសើរដល់វឌ្ឍនៈភាពរបស់ក្រុមការងារ ទោះជាអង្គភាពទើបបង្កើតថ្មី។ អង្គប្រជុំបានធ្វើការពិភាក្សា មានមតិយោបល់ផុលផុស។ លោកជំទាវ បានធ្វើការកែតម្រូវថា យេនឌ័រ មិនមែនគិតតែស្ត្រីនោះទេ បុរសក៏ត្រូវគិត គ្រាន់តែមានការយកចិត្តទុកដាក់ថា តើការទទួលបានរបស់ពួកគាត់គ្រប់គ្រាន់ហើយឬនៅ?

ជាលទ្ធផលនៃកិច្ចប្រជុំ អង្គប្រជុំបានសម្រេច ៖

- សូមផ្តល់ស្ថិតិស្ត្រី ដែលមានបែងចែកច្បាស់ប៉ូលីស ស៊ីវិល តួនាទី នៅក្នុងអង្គភាព ឱ្យច្បាស់ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ ដើម្បីលេខាធិការដ្ឋានបូកសរុបតួរលេខសម្រាប់រៀបចំទិវា ៨មិនា (លោកជំទាវ ព្រំ ចន្ថា ទទួលបន្ទុក)
- រៀបចំកម្មវិធីសង្គម និងមនុស្សធម៌ជូនលោកជំទាវ កែ សួនសុភី មុនទិវា៨មិនា
- សូមផ្តល់របាយការណ៍ប្រចាំឆ្នាំ មិនឱ្យហួសខែកុម្ភៈ ឆ្នាំ២០២៤ និងរបាយការណ៍ត្រីមាស នៅថ្ងៃទី២៥ ខែបន្ទាប់ តាមគម្រូដែលបានផ្តល់ជូន។ លោកជំទាវ រ៉ន សិរីលក្ខិណា បានលើកឡើងថា ដោយសារជាទូទៅក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃត្រូវធ្វើរបាយការណ៍៣ផ្សេងៗគ្នា សម្រាប់ របាយការណ៍ទៅក្រុមប្រឹក្សាជាតិដើម្បីស្ត្រី របាយការណ៍បញ្ជ្រាបយេនឌ័រ និងរបាយការណ៍លើកសកម្ពស់សីលធម៌សង្គម ដូច្នេះសំណូមពរ បង្កើតទម្រង់របាយការណ៍មួយដែលងាយស្រួលសម្រាប់អ្នកបំពេញ និងដកស្រង់បំបែកតាមតម្រូវការ។ អង្គប្រជុំគាំទ្រ។ (លោកជំទាវ ជួញ សុធៃ ទទួលបន្ទុក)
- សូមផ្តល់ធាតុចូល យុទ្ធសាស្ត្រយេនឌ័រ នៅរយៈពេល ៣០ថ្ងៃ ឬ៤៥ថ្ងៃក្រោយកិច្ចប្រជុំនេះ។ យុទ្ធសាស្ត្រត្រូវផ្អែកលើយុទ្ធសាស្ត្រទាំង៧របស់យុទ្ធសាស្ត្រយេនឌ័រក្រសួងមហាផ្ទៃ និងយុទ្ធសាស្ត្រដែលមានស្រាប់ ដោយយោង ផែនការយុទ្ធសាស្ត្របញ្ចកោណមុំទី៤ ផែនការនារីរតនៈទី៦ អនុសាសន៍ទាំង១២របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី(អនុសាសន៍សម្រាប់ក្រសួងមហាផ្ទៃ) គោលនយោបាយកម្មវិធីនានាដែលទាក់ទងការលើកកម្ពស់យេនឌ័រ និងអនុសញ្ញាជាតិ/អន្តរជាតិ ។ យុទ្ធសាស្ត្រដែលអង្គភាពនិមួយៗមានស្រាប់ គួរតែពិនិត្យមើលតើមានបញ្ជ្រាបការលើកកម្ពស់យេនឌ័រដែរឬទេ ពិនិត្យមើលចំនុចខ្លាំង ចំនុចខ្សោយ និងដំណោះស្រាយ ដើម្បីស្រង់ចំនុចដាក់ក្នុងយុទ្ធសាស្ត្រ។ (លោកជំទាវ ឌុច ដាណា ទទួលបន្ទុក)
- អង្គភាពនិមួយៗសូមធ្វើការកែសម្រួល ឬបង្កើតថ្មីនូវរចនាសម្ព័ន្ធរបស់អង្គភាពខ្លួន (លោកជំទាវ សំ រចនា ទទួលបន្ទុក)
- ការប្រមូលរបាយការណ៍ថ្នាក់ក្រោមជាតិ សំណូមពរមានការជួបប្រជុំ៣ខែម្តង ឬ៦ខែម្តង ដូចអណត្តិលោកជំទាវជូ ប៊ុនអេង ដែលធ្លាប់អនុវត្ត (លោកជំទាវ គង់ ស៊ីផា ទទួលបន្ទុក)
- នឹងស្នើសុំគ្រូបង្គោលពីក្រសួងកិច្ចការនារី ដើម្បីបើកវគ្គបណ្តុះបណ្តាលពីយេនឌ័រសម្រាប់ចំណុះថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្រសួងមហាផ្ទៃ និងបង្កើតគ្រូបង្គោលនៅតាមអង្គភាពនីមួយៗ។

កិច្ចប្រជុំបានបញ្ចប់ដោយទទួលបានលទ្ធផលឯកភាពរួម និងទទួលអនុវត្តពីអង្គភាពពាក់ព័ន្ធទាំងអស់។

សូមលោកជំទាវ អនុប្រធានកិត្តិយស មេត្តាទទួលជ្រាបជារបាយការណ៍។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ត្រូវថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

**រ៉ន សិរីលក្ខិណា**